រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១១១ ប្រក.សហវ.រជ**

**ស្តីពីការប្រគល់ភារកិច្ចការងារជូនមន្ត្រីរាជការរតនាគារ**

**ក្រុងព្រះសីហនុ**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញប្រកាសលេខៈ ២១៧ ប្រក-សហវ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការផ្អាកភារកិច្ចការងារមន្ត្រីរាជការ ។

**សំរេច**

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ចការងារជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការរតនាគារក្រុងព្រះសីហនុ ដូចខាងក្រោម ÷

១-លោក **ហ៊ូ ហ៊ាន** អនុប្រធានទី១ រតនាគារក្រុងព្រះសីហនុ ជាប្រធានស្តីទីទទួលបន្ទុកផ្ទាល់ផ្នែករដ្ឋបាល-បុគ្គលិក និង ទទួលបន្ទុកដឹកនាំការងាររួមជំនួសលោកប្រធាន រតនាគារក្រុងព្រះ សីហនុដែលត្រូវផ្អាកភារកិច្ចការងារបណ្តោះអាសន្ន ។

២-លោក **យិន ពិនាយ** អនុប្រធានរតនាគារក្រុងព្រះសីហនុ អោយទទួលបន្ទុកផ្នែកគណនេយ្យ និង បេឡាព្រមទាំងទទួលៈបន្ទុកដឹកនាំការងាររួម នៅពេលអវត្តមានលោកប្រធានស្តីទី ។

៣–លោកស្រី **នន សុយ៉ុន** អនុប្រធានផ្នែកគណនេយ្យ អោយទទួលបន្ទុកដឹកនាំការងាររួមក្នុងផ្នែកគណនេយ្យ ។

**ប្រការ ២** : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១១២ សហវ.ប្រក,ប**

**ស្តីពីការបង្កើតនាយកដ្ឋានអាស៊ាន**

**មណ្ឌលអាសន្ន ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស- រកម ០១៩៦–១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល